# មជ្ឈមណ្ឌលឯកសារកម្ពុជា

BMI0064

**សម្ភាសន៍ជាមួយឈ្មោះ គ្រូច នឹម ភេទប្រុស អាយុ៧៥ឆ្នាំ**

**មុខងាររដ្ឋជនទី ខ្មែរក្រហម«មេឃុំ»**

**មុខងារបច្ចុប្បន្ន«អាចារ្យវត្ត»**

**ស្រុកកំណើតនៅភូមិពាក់បង្អែង ឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ**

**រស់នៅភូមិភ្នំរូង ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ**

**ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០**

**សម្ភាសន៍ដោយៈ សោម ប៊ុនថន**

**០០:៣៥:៣៨**

**២០ទំព័រ**

ប៊ុនថនៈ ជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះ អ៊ំ អ៊ំឈ្មោះអីដែរ?

នឹមៈ ឈ្មោះ គ្រូច នឹម ។

ប៊ុនថនៈ អ៊ំអាយុប៉ុន្មានហើយ?

នឹមៈ ខ្ញុំអាយុច្រើនណាស់ អាយុ៧៥ហើយឥឡូវហ្នឹង ។

ប៊ុនថនៈ ៧៥?

នឹមៈ បាទ ។

ប៊ុនថនៈ ចឹងអ៊ំនៅមាំ អ៊ំនៅធ្វើចំការបានតើ?

នឹមៈ អត់ទេ រាល់ថ្ងៃកូនចៅវាធ្វើ ។

ប៊ុនថនៈ បាទ ។

នឹមៈ ខ្ញុំឈប់ពីរឆ្នាំហើយ រឿងធ្វើចំការណាស់ ឥឡូវនៅវត្ត ។

ប៊ុនថនៈ បាទ!ចឹងអ៊ំស្រុកកំណើតនៅភូមិឃុំអីដែលអ៊ំ?

នឹមៈ ខ្ញុំនៅឃុំត្រពាំងធំតែម្តង ។

ប៊ុនថនៈ ភូមិ?

នឹមៈ ភូមិពាក់បង្អែង ឃុំត្រពាំងធំ ស្រុកត្រាំកក់ ។

ប៊ុនថនៈ បាទ!អ៊ំកាលពីនៅតូចៗហ្នឹងអ៊ំធ្លាប់រៀនដល់ណាដែរ?

នឹមៈ ខ្ញុំរៀនបានថ្នាក់ទី៧ពីដើម ប្រឡងស៊ីធីការ ដល់នេះហើយប្រឡងធ្លាក់ប្រឡងកុងគួកចូលពីដើមណាស់ ដូចជាក្មេងឥឡូវគេប្រឡងយកសញ្ញាប័ត្រហ្នឹងណាស់ ។

ប៊ុនថន៖ បាទ ។

នីម៖ កាលជំនាន់ហ្នឹងវាខ្លាំងជាងឥឡូវនេះ ។

ប៊ុនថន៖ បាទ!និយាយថាខ្លាំងជាង ។

នីម៖ កាលឆ្នាំ១៩៥៧ខ្ញុំប្រឡងជាប់ ។

ប៊ុនថន៖ បាទ!ដលអ៊ីប្រឡងចប់ចឹងទៅ?

នីម៖ ប្រឡងចប់ចឹងទៅ ប្រឡងកុងគួកចូលចឹងទៅកាលជំនាន់ហ្នឹងណាស់ ។

ប៊ុនថន៖ បាទ ។

នីម៖ បារាំងហៅថាប្រឡងកុងគួកចឹងទៅ ដល់ទៅវាធ្លាក់ ដល់ធ្លាក់ចឹងគេឲ្យប្រឡងធ្វើជាប៉ូលីសខ្ញុំ មិនធ្វើ ដល់ហើយខ្ញុំមានប្រពន្ធទៅ ក៏រកស៊ីទៅ ។

ប៊ុនថន៖ រកស៊ីនៅណាវិញ?

នីម៖ រកស៊ីនៅត្រពាំងធំនៅក្នុងភូមិហ្នឹង ។

ប៊ុនថន៖ ចឹងអ៊ីនៅរកស៊ីដល់ឆ្នាំណាបានអ៊ីឈប់?

នីម៖ ខ្ញុំរកស៊ីចាប់តាំងពីឆ្នាំ៥៩ដល់ឆ្នាំ៧០គេកើតរដ្ឋប្រហា ។

ប៊ុនថន៖ បាទ ។

នីម៖ ដល់ឆ្នាំ៧០ហ្នឹងកើតរដ្ឋប្រហាហ្នឹងដល់ឆ្នាំ៧១គេប្រមូលហើយណាមានគោអីចូលរួមគ្នាទៅ ណាស់ ។

ប៊ុនថន៖ បាទ ។

នីម៖ មុនដំបូងចេះ ឆ្នាំ៧០និង៧១នេះគេធ្វើជារបៀបបន្ទាស់ដៃគ្នាណាស់ ។

ប៊ុនថន៖ បាទ ។

នីម៖ ដល់ធ្វើបន្ទាស់ដៃគ្នាមួយក្រុមមានគ្នា១២នាក់ ១២គ្រួសារហ្នឹងទៅ ដល់ធ្វើស្រែ១២នាក់ ហ្នឹងបានប៉ុន្មានទៅ គេចែកផលគ្នា ។

ប៊ុនថន៖ បាទ ។

នីម៖ ដូចថាអូនឯង១២ថាំងក្នុងមួយឆ្នាំ ។

ប៊ុនថន៖ បាទ ។

នីម៖ ខ្ញុំក៏១២ថ្នាំងដូចគ្នាចឹងទៅ ។

ប៊ុនថន៖ ចឹងចែកគ្នាស្មើរចឹងទៅ?

នីម៖ បាទ ។

ប៊ុនថន៖ ចឹងអ៊ីបន្ទាស់ដៃដែរ?

នីមៈ បន្ទាស់ដូចតែគ្នាហ្នឹង ។

ប៊ុនថនៈ តែអ៊ីនៅរកស៊ីទៀតទេ?

នីមៈ អត់ទេ ខុសពីមុនហើយ ដូចថាយើងរកស៊ីជំនួញដួញដូរហ្នឹងគេចេះតែបិតៗទៅណាស់ ។

ប៊ុនថនៈ បាទ ។

នីមៈ គេមិនឲ្យយើងរកស៊ីដូចពីដើម ។

ប៊ុនថនៈ កាលហ្នឹងអ៊ីរកអីដែរ?

នីមៈ កាលហ្នឹងធ្វើតែស្រែហើយខ្ញុំកាលហ្នឹងធ្វើត្នោតអីហ្នឹង ។

ប៊ុនថនៈ ចឹងធ្វើស្ករត្នោត?

នីមៈ បាទ!ធ្វើស្ករត្នោត ព្រោះកាលនោះមិនសូវជាមានរបររកស៊ីធំដុំទេ ។

ប៊ុនថនៈ បាទ ។

នីមៈ បើមានគោមានរទេះចូលព្រៃទៅ កាប់ឈើទៅកាលជំនាន់ហ្នឹង ។

ប៊ុនថនៈ ចឹងកាលជំនាន់ហ្នឹងតា ម៉ុកអីនៅឃុំជាមួយអ៊ីដែរ?

នីមៈ អត់ទេ កាលហ្នឹងមិនដែលឃើញទេ ដល់យូរនោះបានមានពូឈ្មោះ ។

ប៊ុនថនៈ បាទ!ចឹងកាលនៅពីក្មេងអីអ៊ីមានធ្លាប់ឃើញ?

នីមៈ កាលពីក្មេងនៅរៀនមិនដែលស្គាល់ផង ស្គាល់តែចាស់ៗ តែដល់នេះមកគ្រាន់តែមិនបាន ជិតស្និតហ្នឹងគ្នាទេណាស់ ។

ប៊ុនថនៈ បាទ ។

នីមៈ គ្រាន់តែពូឈ្មោះហ្នឹង តែនៅក្នុងឃុំជាមួយគ្នាដែរ ដូចថាចាស់ៗស្រុករមុនហ្នឹងរកស៊ីជួបគ្នាទៅ ហើយយើងក្មេងៗយើងនៅរៀននៅឡើយណាស់ ។

ប៊ុនថនៈ បាទ ។

នីមៈ ជំនាន់នោះ ខ្ញុំនៅរៀនតាំងពីឆ្នាំ៥៨ ជំនាន់ខ្ញុំហ្នឹងច្រើនតែរៀនបារាំងអីនោះ ។

ប៊ុនថនៈ បាទ ។

នីមៈ ជំនាន់ខ្ញុំចូលរៀនថ្នាក់កុមារដ្ឋានអីហ្នឹង រៀនស្រៈ«អ៊ី អ៊ុយ អូ អា ចឹង»រហូតទៅណាស់ ។

ប៊ុនថនៈ បាទ ។

នីមៈ យើងស្រៈ«អ ស្រៈអាហ្នឹង» វា«អ៊ី អ៊ុយ»ហើយ ។

ប៊ុនថនៈ បាទ!ចឹងអ៊ីនៅចេះបារាំងដែលរាល់ថ្ងៃ?

នីមៈ នៅចេះតិចៗដែលរាល់ថ្ងៃ រកនិយាយអីមិនកើតទេចាស់ហើយ ។

ប៊ុនថនៈ បាទ ។

នីមៈ កាលជំនាន់នោះយើងនៅក្នុងអាណានិគមបារាំង កាលណាយើងរៀនមួយថ្ងៃៗចឹងយើងរៀនសរសេរខ្មែរចឹងទៅ គេឲ្យមកប្រែមកជាបារាំង បារាំងមកប្រែមកខ្មែរចឹងទៅណាស់ ។

ប៊ុនថន: បាទ ។

នីមៈ ធ្វើអីក៏ដោយតែងសេចក្តីខ្មែរ តែងសេចក្តីបារាំងចឹងទៅ រៀបឃ្លាវាផ្សេងគ្នា ។

ប៊ុនថន: បាទ!ចុះតា ម៉ុកអីគាត់រៀនដែរ?

នីមៈ គាត់រៀនមុនខ្ញុំ គាត់រៀនគាត់ធ្លាប់បួសអីណាស់ គាត់ចេះច្រើន ។

ប៊ុនថន: បាទ ។

នីមៈ ជំនាន់ហ្នឹងគាត់អ្នបួសអ្នករៀន គាត់មិនមានរវោហាអីទេ តែគាត់ជាអ្នកចេះដឹង ។

ប៊ុនថន: គាត់បងអីប៉ុន្មានឆ្នាំ?

នីមៈ មិនដឹងទេ ឥឡូវគាត់មិនដឹងប៉ុន្មាន គាត់ជំនាន់ឪពុកខ្ញុំនោះ ។

ប៊ុនថន: បាទ!ចឹងជំនាន់ឪពុកអី?

នីមៈ បាទ! គាត់ជំនាន់ឪពុកខ្ញុំ ។

ប៊ុនថន: គាត់៨០?

នីមៈ ៨០ជាងហើយ ខ្ញុំចេះតែថាប៉ុណ្ណឹងទៅមិនដឹងជាប៉ុន្មានអាយុគាត់ ។

ប៊ុនថន: ចឹងនៅពេលរដ្ឋប្រហាហើយហ្នឹងបន្ទាស់ដៃហើយហ្នឹងអ៊ីនៅក្នុងភូមិឃុំហ្នឹងដដែលឬផ្លាស់ទៅណាដែរ?

នីមៈ ខ្ញុំមិនទាន់ផ្លាស់ទេ ដល់ឆ្នាំ៧៦ ខ្ញុំកុនដែលជំនាន់ហ្នឹងនិយាយឲ្យត្រង់ទៅណាស់ ។

ប៊ុនថន: បាទ ។

នីមៈ កុនចេះទេ ដល់ចូលឆ្នាំ៧០ហ្នឹងគេឲ្យខ្ញុំហ្នឹងនិយាយត្រង់ គេឲ្យធ្វើប្រធានភូមិ ។

ប៊ុនថន: បាទ ។

នីមៈ ដល់ចឹងទៅខាងគេអ្នកធ្វើការ គេថាខាងអនុធនសិស្សជំនាន់ហ្នឹងគេមិនយកអ្នកចេះណាស់ ។

ប៊ុនថន: បាទ ។

នីមៈ ខ្ញុំធ្វើបានតែបីខែទេ ដល់ចឹងទៅគេដកខ្ញុំ ដកខ្ញុំហ្នឹងទៅបង្រៀនចាស់ៗខាងអក្ខរកម្មចឹងខាងអក្ខរកម្មហ្នឹងបានបីខែ ដល់ហើយអ្នកភូមិស្រឡាញ់ខ្ញុំច្រើនហ្នឹង អ្នកភូមិថាបើអត់តាហ្នឹង បើបងហ្នឹងគាត់ធ្វើការដឹកនាំប្រជាពលរដ្ឋភូមិអីចឹងវាពិបាក ឲ្យគាត់ទៅបង្រៀនចឹងខាងលើក៏ឲ្យគាត់មកធ្វើអាហ្នឹងវិញមកណាស់ ។

ប៊ុនថន: បាទ ។

នីមៈ ដល់ហើយគេឲ្យខ្ញុំកាន់កងធ្វើប្រឡាយអីចឹង ដល់ខ្ញុំនឹកឃើញភ័យខ្លួននោះ ។

ប៊ុនថុនៈ បាទ ។

នីមៈ នឹកឃើញថា គេយកប្រវត្តិរូបឯងទៅណាចឹងចេះតែខំហើយណាស់ ។

ប៊ុនថុនៈ បាទ ។

នីមៈ ដល់ហើយពួក១៧ ពួកចិនអីទៅពីភ្នំពេញនេះ ។

ប៊ុនថុនៈ បាទ ។

នីមៈ អូនអើយខំមួយថ្ងៃនាំវាធ្វើ ធ្វើខ្លួនឯងហ្នឹងដួកកាប់ផងដឹកប្រឡាយផង ចុះមនុស្សយើងខ្លាចនោះ ។

ប៊ុនថុនៈ បាទ ។

នីមៈ ព្រោះគេរើសតែអ្នកអត់ចេះ ឲ្យធ្វើការធ្វើប្រធានភូមិប្រធានកងអីហ្នឹងណាស់ ។

ប៊ុនថុនៈ បាទ ។

នីមៈ ជំនាន់ហ្នឹងរៀនដល់ថ្នាក់ហ្នឹង យើងមានចេះអីខ្លះហើយណាស់ ។

ប៊ុនថុនៈ បាទ ។

នីមៈ គេមិនសូវគិតគូរយើងទេ ។

ប៊ុនថុនៈ បាទ ។

នីមៈ ចឹងហើយចេះតែបន្ទំគេទៅ កាលខ្ញុំធ្វើការហ្នឹងបានស្អាត បានស្អាតចឹងក៏គេឲ្យមកធ្វើការនៅស្រុកគេនេះ ។

ប៊ុនថុនៈ បាទ ។

នីមៈ មកស្រុកគេហ្នឹង មកខាងភ្នំព្រះនេត្រព្រះ ភ្នំស្រុកហ្នឹង ដល់មកចឹងខំនឹកឃើញថាបងប្អូនមកស្គាល់គ្នាចឹងទៅ ខ្ញុំដឹកនាំទៅបានស្អាត ។

ប៊ុនថុនៈ បាទ ។

នីមៈ និយាយរួមទៅទល់មកឥឡូវនេះ គ្មានពីណាចេះស្អប់ខ្ញុំមួយទេ ហើយសួរមកកូនចៅខ្ញុំអ៊ំ! អ៊ំមកហើយសប្បាយណាស់ ។

ប៊ុនថុនៈ បាទ ។

នីមៈ គាត់មកគាត់ឲ្យដាំដំឡូងមុខផ្ទះក្រោយផ្ទះ ឥឡូវពួកយើងទាំងអស់គ្នាឥឡូវរបស់រួមយើងកុំលួច ឥឡូវរឿងផែនការណាស៊ីអីសុទ្ធតែក្បត់ជាតិ មិនមែនទេឲ្យតែយើងស្មោះត្រង់ដំឡូងមុនផ្ទះក្រោយផ្ទះណាស់ ។

ប៊ុនថុនៈ បាទ ។

នីមៈ ល្ងាចឡើងយើងស្ងោរទៅយើងមានសាច់មាន់នាំកូនហូបទៅ កុំតែលួចរបស់គេ ។

ប៊ុនថនៈ បាទ ។

នីមៈ ដល់ឥឡូវគេចាំត្រង់ហ្នឹង អ៊ីគាត់មកមិនដូចអាមុនទេ ធ្វើអីមិនបានសុទ្ធតែខ្លាំងទាំងអស់ ដំឡូងឯងដាំស៊ីខ្លួនឯងថាខ្លាំង ស៊ីខុសពេលវ៉ៃចោល ។

ប៊ុនថនៈ បាទ ។

នីមៈ ដល់ខ្ញុំធ្វើចឹងមានអី ឥឡូវស្រឡាញ់ខ្ញុំសួរកូនខ្ញុំមើល ទៅនិយាយពីសប្បាយវ៉ា ។

ប៊ុនថនៈ បាទ ។

នីមៈ គាហ្នឹងមកគាត់ដឹកនាំស្អាតណាស់ ។

ប៊ុនថនៈ ចឹងអ៊ំនៅតាកែវបានប៉ុន្មានឆ្នាំបានអ៊ំមកទីនេះ?

នីមៈ តាកែវស្រុកកំណើតខ្ញុំនោះ ។

ប៊ុនថនៈ បាទ! តែនិយាយថាជំនាន់បីឆ្នាំ?

នីមៈ មកនេះកាលឆ្នាំ៧៦ ។

ប៊ុនថនៈ ចឹង៧៦ហ្នឹងផ្លាស់មកនៅណាវិញ?

នីមៈ មកនៅព្រះនេត្រព្រះបានមួយឆ្នាំ ៧៧ខ្ញុំទៅនៅភ្នំស្រុក ។

ប៊ុនថនៈ ព្រះនេត្រព្រះហ្នឹង?

នីមៈ ហ្នឹងស្រុកព្រះនេត្រព្រះតែខេត្តបាត់ដំបង «អ្នកជិតនិយាយថាតំបន់៥» នីមគបវិញថាដឹង ថាតំបន់៥ ហើយតែនៅខេត្តបាត់ដំបងកាលហ្នឹង គេទើបមកបំបែកឥឡូវទេ ។

ប៊ុនថនៈ បាទ ។

នីមៈ ទើបតែមកខេត្តបន្ទាយមានជ័យឥឡូវទេ ។

ប៊ុនថនៈ ចឹងអ៊ំមកនៅខាងស្រុកហ្នឹងតែម្តង?

នីមៈ ខាងស្រុកហ្នឹងតែម្តង កាលហ្នឹងឃុំប្រាសាទ តែស្រុកព្រះនេត្រព្រះ ។

ប៊ុនថនៈ ចឹងព្រះនេត្រព្រះអ៊ំមកដល់ឆ្នាំហ្នឹង?

នីមៈ ឆ្នាំ៧៦ហ្នឹង ។

ប៊ុនថនៈ បាទ! ៧៦ហ្នឹងគណៈស្រុកហ្នឹង?

នីមៈ គណៈស្រុកមកពីហ្នឹងដែរ យាយថែមនោះ ។

ប៊ុនថនៈ បាទ ។

នីមៈ យាយ ថែមឥឡូវមកនៅអន្លង់វែង ។

ប៊ុនថនៈ ចឹងអ៊ំមកដំណាលគាត់ដែរ?

នីមៈ មកជាមួយគ្នា ។

ប៊ុនថនៈ ចឹងកាលហ្នឹងអ៊ីប្រធាន?

នីមៈ ខ្ញុំអត់មានប្រធានអីទេ ។

ប៊ុនថនៈ និយាយអ៊ីចែមនោះ?

នីមៈ កាលហ្នឹងគាត់ប្រធានហើយ ។

ប៊ុនថនៈ ប្រធានគណៈស្រុក?

នីមៈ អើ ។

ប៊ុនថនៈ ចឹងអ៊ីកាលមកដល់នៅខាងអ៊ីវិញអ៊ី?

នីមៈ ខ្ញុំកាលមក៣ខែបានធ្វើប្រវត្តិរូប មកដល់ធ្វើធម្មតាតែយើងមកពីនោះគេចេះតែខ្លាចហើយណាស់ ។

ប៊ុនថនៈ បាទ ។

នីមៈ បីខែបានគេឲ្យខ្ញុំធ្វើការ កាលហ្នឹងបាត់ប្រវត្តិរូបអីទៅ ដល់នេះបានគេឲ្យខ្ញុំធ្វើការវិញ ។

ប៊ុនថនៈ បាទ ។

នីមៈ ធ្វើការហ្នឹងគេឲ្យខ្ញុំកាន់កងធំ កងធំប្រធានសហករណ៍យើងហ្នឹង ។

ប៊ុនថនៈ បាទ!ប្រធានសហករណ៍?

នីមៈ ដល់ខ្ញុំធ្វើបានបីខែគេឲ្យខ្ញុំទៅធ្វើការនៅភ្នំស្រុក គេឲ្យខ្ញុំធ្វើឃុំ ។

ប៊ុនថនៈ បាទ ។

នីមៈ តែប៉ុណ្ណឹងទេ ។

ប៊ុនថនៈ គេហៅសហករណ៍អីវិញអ៊ីនៅខាងព្រះនេត្រព្រះ?

នីមៈ នៅនោះកាលខ្ញុំធ្វើឃុំសហករណ៍ណាំតាវ ។

ប៊ុនថនៈ ណាំតាវ?

នីមៈ ហ្នឹងស្រុកភ្នំស្រុកហើយ ឃុំណាំតាវ កំពីងពួយ ស្រះជីក រោងពានស្រែនេះឃុំមួយដែរ ។

ប៊ុនថនៈ បាទ!ចឹងអ៊ីទៅនៅហ្នឹងទៅនៅខាងភ្នំស្រុកវិញមិនមែននៅជាមួយអ៊ីចែមទេ?

នីមៈ អ៊ីចែមគាត់ជាគណៈតំបន់ហើយ ដល់ខ្ញុំទៅហ្នឹងគាត់ឡើងជាគណៈតំបន់ហើយគាត់លែងស្រុកហើយណាស់ ។

ប៊ុនថនៈ បាទ ។

នីមៈ កាលហ្នឹងជំនួសពីតា ចាយអីហ្នឹង ដល់តា ញឹមអីគាត់តំបន់៥ហ្នឹង ដល់ហើយយាយចែមហ្នឹងត្រូវធំ ។

ប៊ុនថន:	ចឹងក្រោយពីបាត់តា ញ៉ឹមហើយបានគាត់ឡើងគណៈតំបន់?

នឹម:	បាទ!គាត់ឡើងគណៈតំបន់ហើយ ។

ប៊ុនថន:	គេហៅតំបន់អីវិញ?

នឹម:	គេហៅតំបន់៥ ។

ប៊ុនថន:	ចឹងរួមទាំងភ្នំស្រុកអីតំបន់ប៉ុន្មានដែរ?

នឹម:	ហ្នឹងតំបន់៥ដូចគ្នា ចឹងមើលណាស់ កាលជំនាន់ហ្នឹងគេមិនទាន់បំបែកស្រុកច្រើនដូចឥឡូវទេណាស់ ។

ប៊ុនថន:	បាទ ។

នឹម:	កាលហ្នឹងខាងលិចមិនអូរជ្រៅ ។

ប៊ុនថន:	បាទ ។

នឹម:	ហើយស៊ីសាផុននេះក៏ស្រុកមួយដែរ ។

ប៊ុនថន:	បាទ ។

នឹម:	ស្វាយស៊ីសាផុននេះហៅសេរីសោភ័ណ្ឌនេះ ។

ប៊ុនថន:	បាទ ។

នឹម:	៣-ព្រះនេត្រព្រះ ៤-ភ្នំស្រុក ៥-ថ្មពួក ។

ប៊ុនថន:	បាទ ។

នឹម:	ឥឡូវគេហៅស្រុកស្វាយចេកមួយទៀតនេះ ។

ប៊ុនថន:	បាទ ។

នឹម:	ឥឡូវវាច្រើនណាស់ អន្លង់វិលទៀត ។

ប៊ុនថន:	ចឹង៥ស្រុកហ្នឹងនៅក្នុងតំបន់៥?

នឹម:	តំបន់៥ ។

ប៊ុនថន:	ចឹងយាយចែមហ្នឹងគាត់គ្រប់គ្រង?

នឹម:	គ្រប់គ្រងទាំងអស់ហ្នឹង មួយតំបន់ហើយ ។

ប៊ុនថន:	តែកាលអ៊ំទៅដឹងបងគាត់នៅជាគណៈស្រុកទេ?

នឹម:	គណៈស្រុកដល់ហើយគាត់ចូលទៅតំបន់ហ្នឹង កាលហ្នឹងឡើងធំអស់ពីអា ជា តា ញ៉ឹមទៅនោះ ។

ប៊ុនថន:	បាទ!ចឹងកាលមុនគាត់ពីណាវិញគណៈស្រុកព្រះនេត្រព្រះ?

នីមៈ អូស! វាច្រើនណាស់មិនដឹងជាពីណាខ្លះទេ ខ្ញុំមកដូចថាវានេះហើយមានតែតា ញឹមទេគាត់ធំជាងគេតែម្ដង ។

ប៊ុនថនៈ បាទ ។

នីមៈ គាត់ជាគណៈតំបន់គណៈភូមិភាគ ។

ប៊ុនថនៈ ចឹងអ៊ំនៅខាងណាំតាវនោះអ៊ំនៅខាងឃុំ?

នីមៈ ខាងឃុំ ។

ប៊ុនថនៈ គណៈឃុំណាំតាវហ្នឹង?

នីមៈ បាទ! ធ្វើបានតែមួយឆ្នាំហ្នឹងមិនដឹងជាអីណាជងរត់ ។

ប៊ុនថនៈ ចឹងអ៊ំកាលមកពីនោះឆ្នាំ៧៦?

នីមៈ ៧៦ ចាំហើយណាស់ពេញឆ្នាំ៧៦ខ្ញុំនៅខាងព្រះនេត្រព្រះសង្កាត់ប្រាសាទយើងនៅតាមដងស្ទឹងទៅទន្លេសាបនេះ ។

ប៊ុនថនៈ បាទ ។

នីមៈ ដល់ពាក់កណ្ដាល៧៧បានខ្ញុំទៅភ្នំស្រុកហើយណាស់ ។

ប៊ុនថនៈ បាទ ។

នីមៈ កាលទៅដល់ភ្នំស្រុកដំបូងយើងមានសិទ្ធអីទេ គ្រាន់នៅកងធំអីជួយគេចឹងទៅណាស់ ។

ប៊ុនថនៈ បាទ ។

នីមៈ ឲ្យជួយដឹកនាំខាងរទេះអីគេចឹងទៅ ដល់ជិតចូល៧៨ហ្នឹងគេឲ្យខ្ញុំធ្វើឃុំហើយ ។

ប៊ុនថនៈ គេហៅឃុំអីវិញ?

នីមៈ ឃុំណាំតាវ អាហ្នឹងគេធ្វើសហករណ៍ជឿនលឿនគេធ្វើផ្ទះគំរូតម្រៀបគ្នាចឹងទៅណាស់ ។

ប៊ុនថនៈ បាទ! ណាំតាវហ្នឹងមានដឹកទំនប់អីដែរ?

នីមៈ មានដឹកទំបន់ពីរមិនមែនទំនប់ត្រពាំងថ្មទេ ។

ប៊ុនថនៈ បាទ ។

នីមៈ ទំនប់.... ឥឡូវវានៅជាប់ខ្លះដែរ ហើយទំនប់ខាងក្រោមនេះមួយទំនប់ត្រាំត្រសរហ្នឹង អាត្រាំត្រសរបាក់អស់ហើយ ។

ប៊ុនថនៈ បាទ ។

នីមៈ ហើយបើនិយាយទំនប់ធំតែម្ដងគឺទំនប់អាងត្រពាំងថ្មហ្នឹង ។

ប៊ុនថនៈ បាទ ។

នីមៈ ហ្នឹងទំនប់ធំជាងគេបង្អស់ដឹកប្ញស្សីយកទៅដាំតាមទំនប់ហ្នឹងណាស់ ។

ប៊ុនថន៖ បាទ ។

នឹម៖ ប្ញស្សីនៅហ្នឹងដែលឥឡូវហ្នឹង ។

ប៊ុនថន៖ ដាំកុំឲ្យបាក់ទំនប់ហ្នឹង?

នឹម៖ កុំឲ្យបាក់ទំនប់ ឃើញដាប់របស់គេច្រើនដែលហ្នឹង ។

ប៊ុនថន៖ បាទ!ណាំតាវហ្នឹងដាប់ត្រពាំងថ្មដែរ?

នឹម៖ ហ្នឹងឆ្ងាយគ្នាតែដូចដាប់គ្នាចឹង តែស្រុកតែមួយទេ ដូចថាហ្នឹងម៉ាជួរភ្នំស្រុកហ្នឹងមានព្រៃ វែងចឹងទៅផុតណាំតាវហ្នឹង ។

ប៊ុនថន៖ បាទ ។

នឹម៖ ហើយខាងព្រៃចឹងមកគេហៅត្រពាំងថ្មហ្នឹងអាងគេមករហូតមកទល់លិចភូមិខ្ញុំនៅហ្នឹង ។

ប៊ុនថន៖ បាទ ។

នឹម៖ នៅនោះគេហៅទំនប់មួយកំពង់សៀម មួយកូនក្លែង ។

ប៊ុនថន៖ បាទ ។

នឹម៖ ដាប់គ្នា ។

ប៊ុនថន៖ ចឹងនៅខាងឃុំព្រះនេត្រព្រះនេះមានពីណាគ្រប់គ្រងអាងត្រពាំងថ្ម?

នឹម៖ ភ្នំស្រុក ។

ប៊ុនថន៖ ខាងភ្នំស្រុក?

នឹម៖ បាទ ។

ប៊ុនថន៖ និយាយថានៅក្នុងភ្នំស្រុកដែរ?

នឹម៖ បាទ!ខាងព្រះនេត្រព្រះអត់មានចូលហ្នឹងទេ ខុសគ្នា ។

ប៊ុនថន៖ បាទ ។

នឹម៖ អាងត្រពាំងថ្មហ្នឹងអាងធំហ្នឹងក្នុងស្រុកភ្នំស្រុក ។

ប៊ុនថន៖ បាទ ។

នឹម៖ ឃុំត្រពាំងថ្មហ្នឹង អាហ្នឹងឃុំត្រពាំងថ្មឬឃុំពយចារទេ ។

ប៊ុនថន៖ ចឹងអ៊ីត្រពាំងថ្មហ្នឹងគេកសាងនៅសម័យបីឆ្នាំដែរ?

នឹម៖ បាទ!អាហ្នឹងកសាងនៅសម័យបីឆ្នាំ ទំនប់ហ្នឹងមានតាំងពីមុនមកដែលណាស់ ។

ប៊ុនថន៖ បាទ ។

នឹម៖ តែដល់សម័យហ្នឹងយើងខ្វះទឹកអីទៅក៏គេប្រមូលកងចល័តបេះតែនាំគ្នាសែង ។

ប៊ុនថន៖ បាទ ។

នីមៈ សែនទៅត្រង់ណានេះយកឫស្សីទាំងគុម្ពមកដាំ ចេះតែចាក់ដីហ្នឹងទៅណាស់ ធ្វើហ្នឹងទំនង ហ្នឹងគេដែរ ។

ប៊ុនថន: បាទ ។

នីមៈ មួយតំបន់៥ យើងនេះ ដូចថាឥឡូវយកកងចល័តមួយពាន់នាក់ចឹងទៅ សែនដីចាក់ទំនប់ហ្នឹងតែម្តងអត់មានគោអីទេជំនាន់នោះ ។

ប៊ុនថន: បាទ ។

នីមៈ ធ្វើតែហ្នឹងដៃ ។

ប៊ុនថន: ឃើញធំ?

នីមៈ ធំ ។

ប៊ុនថន: នៅខាងហ្នឹងខាងស្រុកខាងណាអ្នកគ្រប់គ្រងវិញ មើលការខុសត្រូវ?

នីមៈ មានពីណាគណៈតំបន់ហ្នឹងមានតែយាយ ចែមអីហ្នឹង ។

ប៊ុនថន: បាទ ។

នីមៈ អាហ្នឹងនៅក្នុងអំណាចរបស់គាត់ណាស់ ។

ប៊ុនថន: បាទ ។

នីមៈ សើច...ហើយយើងនៅខាងក្រោមគាត់ប្រើធ្វើអីចេះតែធ្វើទៅ ។

ប៊ុនថន: ចឹងអ៊ំមកនៅនេះបានរយៈពេលប៉ុន្មានបានតា ញឹមគេចាប់?

នីមៈ តា ញឹមគេចាប់នៅឆ្នាំ៧៧ខ្ញុំមកបានមួយឆ្នាំ ។

ប៊ុនថន: ចឹងបានមួយឆ្នាំបានគេចាប់គាត់?

នីមៈ បាទ ។

ប៊ុនថន: អ៊ំមានដឹងថាយ៉ាងម៉េចបានជាគេចាប់គាត់ដែរ?

នីមៈ យើងនៅនេះគេអត់មានប្រាប់យើងទេ បើគេដឹងមានខាងតំបន់ដូចគ្នាដូចជាខាងស្រុកអីហ្នឹង ណាស់ ។

ប៊ុនថន: បាទ ។

នីមៈ កាលជំនាន់នោះបើមានផែនការអីមកពីលើថាឲ្យយើងធ្វើអីយើងធ្វើហ្នឹងទៅ ដល់គេអ្នកធំៗ គេមិនប្រាប់យើងទេ ។

ប៊ុនថន: បាទ ។

នីមៈ ដូចថាខ្ញុំកាន់ខាងមូលដ្ឋានចឹង គេដឹងថាយើងកសាងសហករណ៍ជឿនលឿនធ្វើផ្ទះគំរូ យើងធ្វើប្រព័ន្ធប្រឡាយ ធ្វើស្រែអីចឹងណាស់ ។

ប៊ុនថនៈ	បាទ ។

នឹម៖	មួយថ្ងៃបានប៉ុន្មានហិចតា ៗ ឲ្យបានគ្រប់ផែនការរបស់គេហ្នឹង ។

ប៊ុនថនៈ	បាទ ។

នឹម៖	ហើយអារឿងផែនការហ្នឹងយើងមិនដឹងរឿងគេចាប់ហ្នឹងយើងមិនបានដឹង អារឿងគេខាងលើយើងមិនសូវដឹងទេ ។

ប៊ុនថនៈ	បាទ ។

នឹម៖	យើងដឹងលុះគ្រាតែឥឡូវនេះមិត្តយើង នៅក្នុងរបស់យើងមិត្តត្រូវមើលសភាពការណ៍ក្នុងមូលដ្ឋានរបស់យើងមានអ្នកមានប្រតិកម្មឬអ្នកណាមានចារកម្មពួកប៉ាវអីពួកសេរីការអីហ្នឹងណាស់ ។

ប៊ុនថនៈ	បាទ ។

នឹម៖	អាហ្នឹងវារត់ចូលព្រៃ រត់ពីព្រៃចូលក្នុងរត់ពីក្នុងចូលព្រៃអីមានបន្កប់ក្នុងនោះចឹងឲ្យយើងចាំមើលចឹងទៅណាស់ យើងមានឈ្លបអីតាមចឹងទៅណាស់ ។

ប៊ុនថនៈ	បាទ ។

នឹម៖	តាមសភាពការណ៍ហ្នឹងរហូតចឹងទៅ ដំនាន់នោះអាដេកព្រៃរាប់មិនឈ្នះ ។

ប៊ុនថនៈ	ដេកព្រៃយ៉ាងម៉េច?

នឹម៖	វាខ្លាចនោះ វាខ្លាចវាមិនដឹងថាសហករណ៍យើងរួមកំលាំងគ្នាកសាងប្រទេសការពារប្រទេសសើច... គេថាបាយរួមចឹងគេថាឃើញវ៉ៃចោលចឹងទៅ ចេះតែភ័យទៅណាស់ ។

ប៊ុនថនៈ	ប្រជាជនហ្នឹង?

នឹម៖	ប្រជាជនហ្នឹងដល់យើងទៅយើងអប់រំបានស្រួលទៅ យើងថាបងប្អូនអើយយើងត្រូវចូលមករួមសាមគ្គីគ្នាកសាងប្រទេសការពារប្រទេសយើងណាស់ ។

ប៊ុនថនៈ	បាទ ។

នឹម៖	កុំទៅនៅដេកព្រៃឲ្យមូសខាំអី មានពីណាគេធ្វើអីទេ ដល់ចឹងទៅខ្លះចូលមកវិញមក ។

ប៊ុនថនៈ	បាទ ។

នឹម៖	ពិសេសរឿងឃុំហ្នឹងហើយ បើឃុំថាល្អទោះជាគ្នាយ៉ាងម៉េចក៏ដោយយើងមកអប់រំគ្នាជួយធ្វើការអីទៅ វាខូចតែអាឃុំហ្នឹងវាចង់យកឈ្មោះដែរ រាយការណ៍យកទៅឲ្យគេទៅអ្នកខាង អ្នកខាងលើយកគ្នាទៅវ៉ៃថ្មនៅភ្នំរយោងទៅជាប់និន្នាការយ៉ាងម៉េច គេយកវ៉ៃចោលក៏មាន ។

ប៊ុនថនៈ	បាទ ។

នីមៈ ជំនាន់ហ្នឹងវាចឹងទេ ។

ប៊ុនថនៈ បាទ ។

នីមៈ អាហ្នឹងយើងនិយាយឲ្យត្រង់ទៅ អារឿងខ្ញុំអត់ទេ ។

ប៊ុនថនៈ បាទ ។

នីមៈ បើចឹងអ្នកគ្រប់គ្នាជំនាន់ហ្នឹងឲ្យទៅស្រុកហ្នឹងទៅបីស្រុកហ្នឹង មិនជឿខ្ញុំដើរតាមខ្ញុំទៅ និយាយពីភូមិមួយៗសប្បាយមែនទែន ។

ប៊ុនថនៈ បាទ!គាត់នៅចូលចិត្តអី?

នីមៈ ចូលចិត្តហ្នឹងស្គាល់ទាំងអស់ ខ្ញុំមិនបាច់ទេឲ្យចេញពីស្វាយទៅ ត្រឹមស្ទួលទៅព្រះនេត្រព្រះ ទៅប្រាសាទទៅណា មួយជួរស្គាល់ទាំងអស់ ។

ប៊ុនថនៈ បាទ ។

នីមៈ រហូតដល់ភ្នំស្រុក ។

ប៊ុនថនៈ បាទ ។

នីមៈ ដល់មកថ្មពួកដូចជាមិនស្គាល់ទេ ខ្ញុំដើរទៅណាក៏គ្មានពីណាវៃខ្ញុំចោល អត់មានឲ្យកូនណាព្រួយខ្ញុំទេ ។

ប៊ុនថនៈ បាទ ។

នីមៈ ខ្ញុំរាល់ថ្ងៃខ្ញុំមិនអួតទេ រឿងរូបខ្ញុំមួយទោះពីខ្ញុំមិនធ្វើស្រែក៏ដោយ បើខ្ញុំទៅដល់ស្រុកហ្នឹងគា អត់មានបានធ្វើស្រែអីទេ មិនបាច់ទេ គ្រាន់តែម្នាក់មួយការ៉ុងដឹកមិនរួចទេ ។

ប៊ុនថនៈ បាទ ។

នីមៈ សើច... ។

ប៊ុនថនៈ ចឹងគេនៅស្គាល់អីដែរ?

នីមៈ ស្គាល់ សួរកូនចៅខ្ញុំមើល ខ្ញុំនៅនឹកឃើញគេរាប់អានខ្ញុំ ខ្ញុំធ្វើសង្ឃទានឲ្យគាត់មកវិញឡាន កូនខ្ញុំអានោះដឹកអង្ករមិនចង់រួចទេ ។

ប៊ុនថនៈ បាទ ។

នីមៈ ស៊ីរួចមួយប្រាំង រឿងខ្ញុំចឹងបានថា យើងធ្វើល្អវាឃើញល្អណាស់ ។

ប៊ុនថនៈ បាទ ។

នីមៈ ហើយខ្ញុំគិតឃើញដោយខ្លួនខ្ញុំ តាំងពីមកចូលព្រៃធ្វើខ្មែរក្រហមជាមួយគេហ្នឹង ។

ប៊ុនថនៈ បាទ ។

នីមៈ ដូចរាងស្រួលជាងគេ គេជឿជាក់លើខ្ញុំគេឲ្យកាន់លុយអូនឯង កងពល៥១៩ធ្វើពាណិជ្ជ ក៏ដោយខ្ញុំទៅទិញយុនឆាយសាំងអីណាប្រាសាទអីណាស្រុកថៃនៅលើខ្ញុំទាំងអស់ ដល់ចុះមកកន្លែងនេះទៀត គេឲ្យកាន់លុយទៀតទាំងកាបូបតែម្តង ។

ប៊ុនថន: បាទ ។

នីមៈ បើខ្ញុំចេះក្បត់មិនខូះទេ ទៅស្រុកវិញ ។

ប៊ុនថន: គេទុកចិត្តអី ?

នីមៈ មកដល់បន្ទាយឆ្មារនេះគេឲ្យកាន់ទៀត អាហ្នឹងហើយដល់ឆ្នាំ៩៦មកដល់៩៦គេឲ្យធ្វើពាណិជ្ជនៅក្នុងភូមិនេះ វិលចុះវិលឡើងប្រមូល គេថាមានតែគាត់ហើយ គេឲ្យធ្វើពាណិជ្ជនៅហ្នឹងទៀត ។

ប៊ុនថន: ពាណិជ្ជនៅហ្នឹងទៀត ?

នីមៈ ពាណិជ្ជលក់ដូរនៅហ្នឹងទៀត ដល់ហើយពីហ្នឹងខាងអ៊ី ឈាង ខាងតា ភាពនេះណាស់ ។

ប៊ុនថន: បាទ ។

នីមៈ កាលហ្នឹងរកបាញ់គ្នា ទ័ពខាងប៉ៃលិនខាង៣២នេះមកពេញត្រង់នេះ នៅពេញហ្នឹងខ្ញុំពាណិជ្ជខ្ញុំនៅកណ្តាល ខ្ញុំគិតថាខ្មែរក្រហមវៃខ្មែរក្រហមមិនដឹងជាទៅណាទេអញ ។

ប៊ុនថន: បាទ ។

នីមៈ នឹកឃើញចឹង ដល់បីថ្ងៃសំរួលគ្នាត្រូវគ្នាវិញ បានដកឆ្ងាយទៅទំរាំតែដកទ័ពស៊ីអាពាណិជ្ជនេះអស់ អង្ករស្អីៗខ្ញុំទិញមកពីថៃអស់រលីង ។

ប៊ុនថន: បើទៅខាងណា ?

នីមៈ ទ័ពយើងហ្នឹងអត់អីស៊ីវាមិនយកស៊ី ។

ប៊ុនថន: បាទ ។

នីមៈ អំបិលអង្ករអីនៅភូមិនេះ បន្ទាប់ពីហ្នឹងមកមិនប្រមូលលុយខ្វះមួយពាន់ខ្វះប្រាំរយចឹងទៅដល់យើងលក់មួយខែចែកផលចំនិញឲ្យគេទៅ ដូចថា២០ភាគរយចឹងទៅ ។

ប៊ុនថន: បាទ ។

នីមៈ ចែកឲ្យចឹងទៅយកអង្ករមកទៀតបែកអារឿងហ្នឹងទៅស៊ីអស់ អស់បានរំលាយអាហ្នឹងចេញ ។

ប៊ុនថន: បាទ ។

នីមៈ ដល់រំលាយចឹងមកចេះនៅខ្វះ ចេះតែរកស៊ីលក់ដូរតិចៗទៅគេរកចាប់អីទៅរហូតដល់ឆ្នាំ២០០០នេះត្រូវយើងបង្កើតឲ្យមានវត្តអីចឹងទៅណាស់ ។

ប៊ុនថន:	បាទ ។

នីម:	ដល់ចឹងខ្ញុំឃើញប្រជាពលរដ្ឋមកពីស្រុកខ្មែរផាប់ទៅរកដីកប់មិនបាន ពីដើមគេធ្វើវត្តភ្នំរំដួលហ្នឹងមួយ ដល់ចឹងទៅខ្ញុំឃើញវេទនាច្រើន ដល់ចឹងទៅខ្ញុំធ្វើសាលាឆទានមួយនៅភ្នំនេះ ។

ប៊ុនថន:	បាទ ។

នីម:	ដល់អូនឯងធ្វើៗចឹងទៅមិនទាន់បានសាលាផងចេះតែធ្វើបុណ្យទៅបានរបស់ចេះតែច្រើនណាស់ ។

ប៊ុនថន:	បាទ ។

នីម:	បានកន្ទាលខ្មើយចានកំសៀវច្រើនចឹងទៅ មិនកើតទេធ្វើច្បាប់ ទៅសុំគេធ្វើវត្ត ។

ប៊ុនថន:	បាទ ។

នីម:	ដល់ហើយខាងរដ្ឋអំណាចថាមួយឃុំគេឲ្យធ្វើវត្តតែមួយណាស់ ។

ប៊ុនថន:	បាទ ។

នីម:	ឲ្យធ្វើពីរយ៉ាងម៉េចបានទៅអ៊ំ គេមិនឃាត់ទេ ដល់ខ្ញុំមិនអស់ចិត្តខ្ញុំស្គាល់គេនៅភ្នំពេញ ។

ប៊ុនថន:	បាទ ។

នីម:	ធ្លាប់ស្គាល់នៅជាមួយគ្នា វានៅខាងក្រសួងមហាផ្ទៃដល់ទៅទាក់ទងវាទៅ ចឹងអ៊ឹងឯងធ្វើវត្តចាំខ្ញុំទាក់ទងខកញ្ញាគេ ខាងអាចារ្យសម្តេចទេព វង្ស ដល់ខ្ញុំទៅខ្ញុំទៅដល់សម្តេចទេពវង្ស ។

ប៊ុនថន:	បាទ ។

នីម:	ទៅលោកថា ញោម រឿងបុណ្យអត់មានពីណាហាមឃាត់ទេ ឲ្យតែយើងធ្វើកើត១០គ្រួសារក៏ដោយធ្វើទៅបានជាខ្ញុំធ្វើ ។

ប៊ុនថន:	បាទ ។

នីម:	ដល់ហើយពុទ្ធបរិស័តថា បើចឹងមានពីណាទេ គាត់តាំងពីដើមមកមានតែគាត់ទេ តាំងពីសង្គ្រាមមកដល់នេះឲ្យខ្ញុំកាន់លុយវត្តហ្នឹងទៀតចូល១០ឆ្នាំហើយនេះ វត្តហ្នឹង ។

ប៊ុនថន:	វត្តអីវិញ?

នីម:	វត្តបឹងបេងហ្នឹង ឥឡូវពីណាមកក៏យកលុយមកឲ្យខ្ញុំដែរ ។

ប៊ុនថន:	បាទ ។

នីម:	អូនឯងចាំមើលខ្ញុំធ្វើមួយឆ្នាំនេះ កាលឆ្នាំទៅមិញសរសរឈើរន្តឹងទេ ហើយឆ្នាំនេះខ្ញុំមានជញ្ជាំងមានដំបូលចាក់សាបហើយមានបាឡាំងគំនូរខាងទៀត ។

ប៊ុនថន:	បាទ ។

នឹម:	ដូចជាគេមានជំនឿថា តានេះតាំងពីសម័យមុនដល់សម័យនេះ គាត់ដូចជាអ្នកចិត្តធម៌មិនចង់បានគេមើលធនធានរបស់យើងថាកូនរបស់គាត់ គាត់មិនចង់បានអារបស់ក្តៅហើយឲ្យមានបាបកម្មគាត់ទៅជាតិមុខទេ ។

ប៊ុនថន:	បាទ ។

នឹម:	គេមានជំនឿហ្នឹងហើយបានគេចេះតែឲ្យលុយខ្ញុំនេះ បានជាខ្ញុំធ្វើកើតអត់មានខកញ្ញាអត់មានឯកឧត្តមណាមកធ្វើទេ ។

ប៊ុនថន:	បាទ ។

នឹម:	បានជំនឿចឹងនិយាយត្រង់រឿងប្រវត្តិរបស់ខ្ញុំ ។

ប៊ុនថន:	ចឹងអឺចង់សួរត្រឡប់ទៅក្រោយបន្តិច នៅខាងតំបន់៥ហ្នឹងយាយ ថែមចូលក្រោយអឺកាលហ្នឹងប្តូមកមុនអឺ?

នឹម:	មកដំណាលគ្នា ។

ប៊ុនថន:	ចឹងមានការផ្លាស់ប្តូរចាស់ៗចេញ?

នឹម:	អត់មានទេ ។

ប៊ុនថន:	កាលគាត់ចូលមក?

នឹម:	ចូលមកដល់ហើយបានគេចាប់អ្នកធំៗហ្នឹង តា ជា តា ញឹម គេធ្វើមុនស្រុកនេះណាស់គេមានផ្លាស់ ។

ប៊ុនថន:	បាទ ។

នឹម:	តែមិនដឹងថាជាគេដកមកណាទៅណាទេ ខ្ញុំមិនបានដឹង ។

ប៊ុនថន:	បាទ ។

នឹម:	ដកមកចឹងដូចថាពួកយើងខាងនិរតីមកដូចថាអ្នកលំដាប់ខាងបក្សជនគេធ្វើយូរៗហើយមកគេចេះតែឡើងទៅ ។

ប៊ុនថន:	បាទ ។

នឹម:	ធ្វើតាមហ្នឹងទៅ ដូចជាតា រៀមអឺហ្នឹងគាត់ជាប្រធានសន្តិសុខតំបន់អឺចឹងទៅណាស់ ។

ប៊ុនថន:	បាទ ។

នឹម:	ហើយខ្មោចតា ប៉ុលអឺហ្នឹងឡើងតាមហ្នឹង ។

ប៊ុនថន:	ចឹងកាលហ្នឹងអឺនៅខាងភ្នំស្រុកនេះរហូតដល់ចែង៧៩?

នឹម:	បាទ!៧៩រត់ចូលព្រៃ ។

ប៊ុនថន: ឃុំអីវិញកាលហ្នឹង?

នឹម: ឃុំណាំតាវ ។

ប៊ុនថន: ចឹងកាលដំបូងអ៊ំទៅណាវិញ?

នឹម: ខ្ញុំរត់ចូលព្រៃកូនក្មេង រត់ទៅពិបាកណាស់ម្តងចេះទៅម្តងចុះទៅទំរាំតែទាក់ទងគ្នា ដល់ទៅចឹងទៅ ទៅនៅភ្នំដងរែក ។

ប៊ុនថន: បាទ ។

នឹម: ទៅនៅដងរែក៧៩ហ្នឹងយូរដែរ ៥ទៅ៦ខែទៅធ្វើស្រែនៅតា ខ្មួយចឹងទៅ ។

ប៊ុនថន: បាទ ។

នឹម: ដល់យូរចឹងទៅបានដល់ឆ្នាំ៨០ចូលថៃហើយ ។

ប៊ុនថន: ម៉េចបានរត់ទៅហ្នឹង?

នឹម: បើមិនរត់ណាបើយើងចូលក្នុងខ្លាចវៀតណាមយួន ចឹងយើងមិនចូលថៃ ។

ប៊ុនថន: បាទ ។

នឹម: ដល់ចូលថៃចឹងទៅបានថៃដឹកយកមកដាក់បឹងក្រកួនភ្នំឆត្រយើងនេះ ។

ប៊ុនថន: បាទ ។

នឹម: នៅហឹងគេចែកអង្ករឲ្យហូបហើយ កាកក្របាទហើយ កាលហ្នឹងមានកាកក្របាទហើយ ។

ប៊ុនថន: ចឹងភ្នំឆត្រហ្នឹងនៅថ្មពួក?

នឹម: ហ្នឹងហើយស្រុកថ្មពួក ។

ប៊ុនថន: ចឹងមកដាក់នៅហ្នឹង?

នឹម: ដាក់នៅហ្នឹងបើកអង្ករអីនៅហ្នឹង នៅហ្នឹងបានយូរណាស់ ។

ប៊ុនថន: នៅដល់ឆ្នាំណា?

នឹម: កូនគាត់និយាយប្រាប់បន្ត ចាំមើលអូន កាលឆ្នាំ៨០គេមានជំរំនៅតាមជាយដែន មើលមានជំរំថ្មី ជំរំណងចាន់ ខាងខ្មែរក្រហមមានចំការគរ មានភ្នំឆត្រមានព្រៃមាន់គេហៅបឹងក្រកួនរាល់ថ្ងៃហ្នឹង មានជំរំនៅតាមជាយដែន ។

ប៊ុនថន: បាទ ។

នឹម: ហើយកាលហ្នឹងគេមានកំលាំងទ័ព ។

ប៊ុនថន: បាទ ។

នឹម: កំលាំងទ័ពខ្មែរក្រហមគេចែកទ័ពអីចឹង ប៉ុរាក៏មានចឹងដែរ មនុស្សមានរត់មកពីក្នុងនេះចិនទៅអាមេរិចច្រើនណាស់ ។

ប៊ុនថន៖ បាទ ។

នឹម៖ កាលហ្នឹងវត់ឆ្វងកាត់តាមហ្នឹង ។

ប៊ុនថន៖ ចឹងអ៊ីមកដល់នេះនៅឆ្នាំ៨៣?

នឹម៖ ហ្នឹងហើយ៨៣ ។

ប៊ុនថន៖ អ៊ីនៅត្រង់ណា?

នឹម៖ នៅត្រង់អូរនេះ ។

ប៊ុនថន៖ ចឹងនៅនេះគេហៅភូមិសាស្រ្តអី?

នឹម៖ កាលហ្នឹងនៅតាមអូរហ្នឹងមានបានមានផ្ទះអីទេណាស់ មានតែកៅស៊ូតើ ។

ប៊ុនថន៖ បាទ ។

នឹម៖ យើងប្រក់ហើយដាក់អង្រឹងអីទៅ មានកូនច្រើនទៅយើងធ្មឹកខ្មែងក្រាលកន្ទាលដេកហ្នឹងដីណាស់ ។

ប៊ុនថន៖ បាទ ។

នឹម៖ ពិបាកណាស់យើងធ្វើផ្ទើរអីតិចតួចទៅ ។

ប៊ុនថន៖ កាលហ្នឹងមានកូនប៉ុន្មាននាក់អ៊ី?

នឹម៖ កាលមកហ្នឹងមានកូន៥នាក់ ខ្ញុំមកដល់នេះកូននៅលីវទាំងអស់ ។

ប៊ុនថន៖ បាទ!មកដល់ដំបូងហ្នឹង?

នឹម៖ មកដល់ដំបូងនៅលីវសុទ្ធតែកំលោះក្រមុំហើយ ពេញប្រើដឹកជញ្ជូនអីហ្នឹង ។

ប៊ុនថន៖ ចឹងកាលមកដល់ហ្នឹងដូចជាប្រវត្តិវត្តអីមាននៅ?

នឹម៖ អត់មានទេ អត់មានវត្តទេ ភូមិណាក៏មិនទាន់មានដែរ កាលហ្នឹងមានតែកន្លែងសាតាំង១ ដែលអភិបាលស្រុកគាត់បណ្តុះបណ្តាលធ្វើនេះ ។

ប៊ុនថន៖ បាទ ។

នឹម៖ ហ្នឹងគេហៅសាតាំង១ ហ្នឹងជាកន្លែងស្តេចអីហ្នឹងណាស់ ។

ប៊ុនថន៖ ចឹងវត្តអីកើតមាននៅឆ្នាំណា នៅម៉ាឡៃកើតវត្តឆ្នាំណា?

នឹម៖ នៅម៉ាឡៃកើតវត្តនៅឆ្នាំ៩៦ កើតមុនគេបង្អស់នៅវត្តម៉ាឡៃនេះ ។

ប៊ុនថន៖ ចឹងវត្តចាស់ហ្នឹង?

នឹម៖ វត្តចាស់ម៉ាឡៃហ្នឹង ដល់យើងមានវត្តមានអីដែលយើងធ្វើបាន មានតែវត្តយើងបានគ្រប់គ្នានេះណាស់ ។

ប៊ុនថន៖ មានលោកមានអី?

នីមៈ	មានលោកមានអី ម៉ាខ្សែមានតាំងពីឆ្នាំ៩០តាមមើលទៅ  កាលខ្ញុំមិនបាននៅនេះទេ ។

ប៊ុនថន: 	បាទ ។

នីមៈ	ខ្ញុំនៅដងរែក បានចុះពីភ្នំដងរែកមកបានមកនៅថ្មពួកវិញខ្ញុំណាស់ ។

ប៊ុនថន: 	បាទ ។

នីមៈ	ដល់ហើយមកនៅនេះក្រោយគេ ឆ្នាំ៧៦បានខ្ញុំមកដល់នេះ ដល់ខ្ញុំមកឃើញមានវត្តហើយ កាលហ្នឹង៩៨ខែបោះឆ្នោតហើយ ដឹងហើយកាលហ្នឹងបោះឆ្នោតនៅបន្ទាយឆ្មារហ្នឹងយើងនេះ ។

ប៊ុនថន: 	បាទ ។

នីមៈ	បោះឆ្នោតកាលហ្នឹងខ្ញុំចាប់ខាងសម្ដេចនរោត្តមរិទ្ធិសើច... ។

ប៊ុនថន: 	ចឹង៩០ប៉ុន្មានបានអ៊ឹមកដល់ភូមិនេះ?

នីមៈ	កាលហ្នឹង៩៦ កាលហ្នឹងធ្វើសមាហរណ៍កម្មហើយ ។

ប៊ុនថន: 	បាទ ។

នីមៈ	ចេញចូលបានហើយ ។

ប៊ុនថន: 	ចឹង៨៣អ៊ឹមកនៅនេះ?

នីមៈ	អាហ្នឹងវត្តផ្សេង ។

ប៊ុនថន: 	បាទ ។

នីមៈ	៨៣ខ្ញុំមកពីភ្នំឆត្រមកចូលដីថៃ ចូលដីថៃបានគេយកមកដាក់នៅភូមិនេះ ។

ប៊ុនថន: 	បាទ ។

នីមៈ	កាលហ្នឹងនៅគេបើកអង្គរឲ្យហូបទេ កាលឆ្នាំ៨៣ហ្នឹងយួនវាំនៅភ្នំនេះ ។

ប៊ុនថន: 	បាទ ។

នីមៈ	នៅភ្នំហ្នឹងគេយកពួកខ្ញុំទៅដាក់នៅដីថៃ ។

ប៊ុនថន: 	បាទ ។

នីមៈ	នៅដីថៃ៥ឆ្នាំ គិតទៅ៨៣-៨៤ចូលដីថៃចឹងទៅដល់ឆ្នាំ៩០បានគេរំសាយវិញ ។

ប៊ុនថន: 	បាទ ។

នីមៈ	ហ្នឹងគេថាអង្គភាពណាទៅនៅអង្គភាពហ្នឹងវិញទៅណាស់ ខ្ញុំកូនច្រើនគេឲ្យទៅដងរែកទៅដងរែកទៅ វាខុសគ្នាចឹងតើ កាលហ្នឹងចេញពីថៃហើយ ។

ប៊ុនថន: 	បាទ ។

នីមៈ	កាលនៅថៃហ្នឹងមានមូលដ្ឋានធ្វើសាលារៀនមានពេទ្យមានអី ហ៊ឺហាណាស់ ។

ប៊ុនថន៖ បាទ ។

នឹម៖ អាឈើស្រុកថៃវាមកសុំវាទៅ ។

ប៊ុនថន៖ អាឈើស្រុកថៃហ្នឹងយកមកធ្វើផ្ទះអីទៅ?

នឹម៖ ហ្នឹងឈើនៅដីថៃហ្នឹង គេឲ្យដីមួយគីឡូបួនជ្រុងហ្នឹង ផ្ទះសាលារៀនអីកូនយើងអីរៀនដូចតែគ្នាហ្នឹង ។

ប៊ុនថន៖ តែរៀនខ្មែរឬមួយរៀនថៃ?

នឹម៖ រៀនខ្មែរ ហើយថៃខ្លាចយើងចង់ផាប់ហ្នឹង ថៃខ្លាចខ្មែរក្រហម ។

ប៊ុនថន៖ បាទ ។

នឹម៖ ខ្មែរក្រហមមានតម្រួតមានប៉ូលីសដូចតែគ្នា នៅវាហ្នឹង ។

ប៊ុនថន៖ បាទ ។

នឹម៖ មានឡានបើកបរមកនេះឡានថៃគេជូន ដូចថាមេទ័ពចង់ទៅលេងផ្ទះគេជូនទៅដាក់ចឹងទៅ ។

ប៊ុនថន៖ បាទ!ចឹងកាលហ្នឹងអ៊ំនៅកងដដែល?

នឹម៖ អត់ទេ ខ្ញុំចាស់ទៅគេឲ្យធ្វើខាងគ្រឿងសំណង់ គេឲ្យធ្វើសាលារៀនធ្វើអីចឹងទៅណាស់ ។

ប៊ុនថន៖ បាទ ។

នឹម៖ ខ្ញុំនៅខាងមូដ្ឋានរហូតចឹងទៅ ។

ប៊ុនថន៖ បាទ ។

នឹម៖ ខ្ញុំលែងធ្វើទ័ពធ្វើអីហើយ ។

ប៊ុនថន៖ ចឹងអ៊ំដងវែកហើយ៩៦បានអ៊ំមកនេះ?

នឹម៖ បាទ ។

ប៊ុនថន៖ ចឹងមកនៅហ្នឹងជាអចិន្ត្រៃយ៍រហូតដល់បច្ចុប្បន្ន?

នឹម៖ មកដល់ឥឡូវហ្នឹង១៩ឆ្នាំ ។

ប៊ុនថន៖ បាទ!ចង់សួរអ៊ំដែល កាលពីមុនសមាហរណ៍កម្មដែលធ្លាប់បើករបបអីចឹង ចឹងដូចជាក្រោយមកសមាហរណ៍កម្មហើយជីវភាពរស់នៅអីខុសគ្នាយ៉ាងម៉េចដែរ?

នឹម៖ នេះវាដាច់ហើយអ្នកជាប់តាំងពីឆ្នាំ៩៦មកមានអត្តភាពដែលគេបំរើក្នុងជួររបស់គេគេធ្លាប់ធ្វើការពារទឹកដីហ្នឹងគេនៅបើអីណាស់ ។

ប៊ុនថន៖ បាទ ។

នឹម៖ យើងជាប្រជាពលរដ្ឋអី គេឲ្យដីធ្វើស្រែចំការអីទៅ ។

ប៊ុនថន៖ បាទ ។

នីមៈ ដំនាន់នោះមានកាំបិតពូថៅអីចេះតែកាប់ទៅ ចាយចឹងទៅណាស់ យើងធ្វើទៅថៃគេចូលមកទិញទៅយើងបានលុយកាក់អី សន្សំទៅខ្លះគេទិញនេះនោះអីទៅ ។

ប៊ុនថនៈ បាទ ។

នីមៈ រហូតចឹងមកដល់យើងធ្វើទៅ រឿងរបបចឹងទេ គេឲ្យកាលយើងកំពង់តែសង្រ្គាម កាលហ្នឹងគេបើកឲ្យមែន ។

ប៊ុនថនៈ បាទ ។

នីមៈ អាហ្នឹងគេបើកឲ្យគ្រប់គ្រាន់ ដល់ហើយចឹងមកគេរៀបរយទៅតាមនេះវិញហើយ ។

ប៊ុនថនៈ បាទ ។

នីមៈ អ្នកធ្វើការអ្នកអត់ចឹងទៅណាស់ ។

ប៊ុនថនៈ បាទ ។

នីមៈ ដូចជាអ្នកគ្រូបង្រៀនសិស្សទៅអាហ្នឹងរបបគេមាន ។

ប៊ុនថនៈ បាទ!ចឹងខ្ញុំអត់មានអីសួរអ៊ំទៀតទេ?

នីមៈ បាទ ។

ប៊ុនថនៈ អរគុណអ៊ំច្រើន ។

នីមៈ បាទ ។

**«ចប់»**